# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

**Ministry of Commerce**

No. ១៤១ MoC / M 2002

ភ្នំពេញ, ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០២

## ប្រកាស

## ស្តីពីការផ្ទេរទ្រព្យសម្បត្តិអចលនវត្ថុ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ៥៤អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

-បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១ :** ផ្ទេរការគ្រប់គ្រងទីតាំងផ្ទះមួយល្វែងលេខ ៣៣២ អឺ០ ផ្លូវលេខ៣ ភូមិមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ជូនទៅ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ( នាយកដ្ឋានកាំកុងត្រូល ) ជាអ្នកគ្រប់គ្រងវិញ ដោយផ្តាច់ចេញពីការគ្រប់គ្រង របស់មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង ។

**ប្រការ២:** មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង ត្រូវជំរះបញ្ជីអចលនវត្ថុខាងលើ ចេញពីបញ្ជីសារពើភណ្ឌរបស់ខ្លួន ព្រមជាមួយ នោះ នាយកដ្ឋានកាំកុងត្រូល ត្រូវកត់ត្រាចូលក្នុងបញ្ជីសារពើភណ្ឌអចលនទ្រព្យ របស់ខ្លួនដែរ ។

**ប្រការ៣:** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ មន្ទីរពាណិជ្ជកម្មបាត់ដំបង នាយកដ្ឋានកាំកុងត្រូល ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

<u>ចំលងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាលាខេត្តបាត់ដំបង
-ដូចប្រការ៣ "ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ